# ស្ថានទូតអូស្ត្រាលី ភ្នំពេញ

## <u>សេចក្តីប្រកាសព័ត៌មាន</u>

ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២

## អូស្ត្រាលីគាំទ្រច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់នៅកម្ពុជា

ថ្ងៃនេះ ឯកឧត្តម ព្រឹទ្ធសមាជិក Tim Ayres ឧបការីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាឧបការីរដ្ឋមន្ត្រីក្រសួងផលិតកម្ម របស់អូស្ត្រាលី បានចូលរួមជាមួយ ឯកឧត្តម ប៉ាន សូរស័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា បើកដំណើរការជាផ្លូវការនូវ កម្មវិធីភាពជាដៃគូនៃកិច្ចការពារអ្នកប្រើប្រាស់កម្ពុជា – អូស្ត្រាលី Cambodia-Australia Consumer Protection Partnership (CACPP) នៅខេត្តសៀមរាប។

កម្មវិធីនេះ មានថវិកា ១,៣៥ លានដុល្លាអូស្ត្រាលី សម្រាប់រយៈពេល៣ឆ្នាំ ក្នុងភាពជាដៃគូ រវាងគណៈកម្មការកិច្ចការប្រកួតប្រជែង និងការពារអ្នកប្រើប្រាស់របស់អូស្ត្រាលី (Australian Competition and Consumer Commission - ACCC) និង អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ របស់កម្ពុជា (Cambodian Consumer Protection Competition and Fraud Directorate-General) ដែលមានគោលបំណងបង្កើត និងពង្រឹងសមត្ថភាពមន្ត្រីកម្ពុជា ដើម្បីគាំទ្រដល់ការអនុវត្តច្បាប់ការពារអ្នកប្រើប្រាស់ និងកិច្ចការប្រកួតប្រជែង អោយមានប្រសិទ្ធភាព។

សកម្មភាពនានានៅក្រោមកម្មវិធីនេះ រួមមាន ការបង្កើតជំនាញស៊ើបអង្កេត និងទំនាក់ទំនងជាមួយស្ថាប័នផ្សេងៗខាងក្រៅ ការបង្កើតវិធានការស៊ើបអង្កេត ការផ្តល់ការណែនាំដល់បុគ្គលិក និងការសម្របសម្រួលទំនាក់ទំនងអន្តរជាតិកាន់តែទូលំទូលាយ។ កម្មវិធីនេះគាំទ្រដល់ការអនុវត្តរបស់កម្ពុជានូវច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ឆ្នាំ២០១៩ និងច្បាប់ស្តីពីការប្រកួតប្រជែងឆ្នាំ២០២១ ហើយជាផ្នែកមួយនៃកញ្ចប់ជំនួយរួម ដើម្បីជំរុញការស្តារសេដ្ឋកិច្ចក្នុងតំបន់ ក្រោយវិបត្តិជំងឺកូវីដ-១៩។

ឯកឧត្តម ព្រឹទ្ធសមាជិក Tim Ayres បានមានប្រសាសន៍ថា "កម្មវិធីភាពជាដៃគូនៃកិច្ចការពារអ្នកប្រើប្រាស់កម្ពុជា – អូស្ត្រាលី ដែលយើងកំពុងដាក់ឱ្យដំណើរការនៅថ្ងៃនេះ គឺជានិមិត្តសញ្ញាដ៏អស្ចារ្យមួយនៃការតភ្ជាប់ទំនាក់ទំនងរវាងប្រទេសយើងទាំងពីរ"។

កម្មវិធីនេះនឹងជួយកម្ពុជា អោយបានជួបនិងសហការជាមួយ អ្នកជំនាញជាន់ខ្ពស់ មកពី គណៈកម្មការកិច្ចការប្រកួតប្រជែង និងការពារអ្នកប្រើប្រាស់របស់អូស្ត្រាលី ប្រកបដោយនិរន្តរភាព និងយូរអង្វែង ព្រមទាំងជួយកម្ពុជាបង្កើត និងភ្ជាប់ទំនាក់ទំនង កាន់តែរឹងមាំជាមួយ សហការីធ្វើការផ្នែកកិច្ចការពារអ្នកប្រើប្រាស់ និងកិច្ចការប្រកួតប្រជែង នៅតាមបណ្តាប្រទេសនៅអាស៊ាន។

កម្មវិធីនេះ បន្ថែម និងពង្រឹង ការងាររបស់ប្រទេសអូស្ត្រាលី ក្រោមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ (AANZFTA) អោយកាន់តែទូលំទូលាយ និងជាផ្នែកមួយនៃគំនិតផ្តួចផ្តើមរបស់ ភាពជាដៃគូមេគង្គ-អូស្ត្រាលី ដែលមានថវិការសរុប ចំនួន ២៣២ លាន ដុល្លាអូស្ត្រាលី ដើម្បីជួយប្រទេសនៅតាមតំបន់មេគង្គ ស្តារឡើងវិញពីការរាតត្បាតនៃជំងឺកូវីដ-១៩។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au